ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការពារជាតិ

សារជូនពរ

សូមគោរពជូន

**សម្តេចអគ្គមហាពញ្ញាចក្រី គត្តព្រឹទ្ធបណ្ឌិត ហេង សំរិន ប្រធានរដ្ឋសភា**
**នៃព្រះរាជាណាចក្រកម្ពុជា ក្នុងឱកាសចូលឆ្នាំថ្មីឆ្នាំសកល២០២១**

**សម្តេចអគ្គមហាពញ្ញាចក្រី ជាទីគោរពដ៏ខ្ពង់ខ្ពស់ !**

ក្នុងឱកាសដ៏មហានក្ខត្តឫក្ស ប្រកបដោយសេចក្តីសោមនស្សរីករាយ នៃទិវាចូលឆ្នាំថ្មីឆ្នាំសកល ២០២១ តាងនាមថ្នាក់ដឹកនាំក្រសួងការពារជាតិ ព្រមទាំងនាយទាហាន នាយទាហានរង និងពលទាហានទាំងអស់ នៃកងយោធពលខេមរភូមិន្ទ ក្នុងនាមខ្ញុំនិងភរិយា សូមជូននូវសព្ទសាធុការពរជ័យ សិរីមង្គល វិបុលសុខ មហា-ប្រសើរ ជូន **សម្តេចអគ្គមហាពញ្ញាចក្រី គត្តព្រឹទ្ធបណ្ឌិត** សូមទទួលបាននូវសុខភាពល្អបរិបូរណ៍កម្លាំងកាយមាំមួនខ្លាំងក្លា ប្រាជ្ញាឈ្លាសវៃ ជន្មាយុយឺនយូរ ដើម្បីបន្តដឹកនាំរដ្ឋសភាជាតិ ដែលជាស្ថាប័ននីតិប្បញ្ញត្តិ នៃព្រះរាជាណាចក្រកម្ពុជា ឱ្យសម្រេចបាននូវលទ្ធផលត្រចះត្រចង់ថ្មីៗថែមទៀត។

នាឱកាសដ៏ឧត្តុង្គឧត្តមនេះ យើងខ្ញុំទាំងអស់គ្នា សូមសម្តែងនូវសេចក្តីគោរព និងស្មាមីភក្តិយ៉ាងជ្រាលជ្រៅបំផុត មិនអាចបំភ្លេចបានចំពោះសកម្មភាពស្នេហាជាតិប្រកបដោយគំរូវីរភាពដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហា-ពញ្ញាចក្រី គត្តព្រឹទ្ធបណ្ឌិត** តែងតែបានយកអស់កម្លាំងកាយចិត្ត និងរាល់បទពិសោធន៍ក្នុងការដឹកនាំរដ្ឋសភាពង្រឹងនីតិប្បញ្ញត្តិជាស្ថាប័នកំពូលរបស់ជាតិប្រកបដោយសក្តានុពល ដើម្បីនាំនាវាកម្ពុជាឆ្ពោះទៅរកនីតិរដ្ឋរឹងមាំ ដែលជាមូលដ្ឋានគ្រឹះក្នុងការអភិវឌ្ឍប្រទេសជាតិប្រកបដោយនិរន្តរភាព និងភាពរុងរឿងស្របតាមបំណងប្រាថ្នារបស់ប្រជាពលរដ្ឋ។

ជាថ្មីម្តងទៀត ក្នុងនាមថ្នាក់ដឹកនាំក្រសួងការពារជាតិ និងកងយោធពលខេមរភូមិន្ទទាំងមូល ក្នុងនាមខ្ញុំនិងភរិយា សូមលើកហត្ថបួងសួងចំពោះគុណបុណ្យព្រះរតនត្រ័យ និងវត្ថុស័ក្តិសិទ្ធិទាំងឡាយក្នុងលោកសូមព្រះអង្គតាមជួយបីបាច់ថែរក្សាប្រោះព្រំសព្ទសាធុការពរជ័យជូនចំពោះ **សម្តេចអគ្គមហាពញ្ញាចក្រី គត្តព្រឹទ្ធបណ្ឌិត** និង**លោកជំទាវ** ព្រមទាំងបុត្រាបុត្រី **ចៅប្រុសចៅស្រី**ជាទីស្រឡាញ់ សូមបានសមប្រកបនូវពុទ្ធពរទាំងបួនប្រការ គឺ **អាយុ វណ្ណៈ សុខៈ ពលៈ** កុំបីឃ្លៀងឃ្លាតឡើយ ។

សូម **សម្តេចអគ្គមហាពញ្ញាចក្រី គត្តព្រឹទ្ធបណ្ឌិត ហេង សំរិន ប្រធានរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា** ទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំបាទ។

ថ្ងៃចន្ទ ១៤កើត ខែ បុស្ស ឆ្នាំជូត ទោស័ក ព.ស.២៥៦៤
រាជធានីភ្នំពេញថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ២០២០
**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ**

សម្តេចពិជ័យសេនា **ទៀ បាញ់**

វិថីហ្សកនីមីត្រូវ សង្កាត់មិត្តភាព ខណ្ឌ៧មករា រាជធានីភ្នំពេញ ទូរស័ព្ទ០២៣ ៨៨៣ ២៧៨: generalsec@mod.gov.kh